# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

## របាយការណ៍កិច្ចប្រជុំ
## ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

**១. ថ្ងៃ ខែ ឆ្នាំ ៖** ថ្ងៃសុក្រ ២រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៤។

**២. ទីកន្លែង ៖** អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធនិម្មិត(Zoom)។

**៣. ប្រធាន និងសមាសភាពចូលរួម ៖**

៣-១- ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៣-២- សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធ ដែលមានសមាជិកចូលរួមនៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ចំនួន៣៥រូប និងតាមប្រព័ន្ធនិម្មិត(Zoom) ចំនួន៣០រូប សរុបចំនួន៦៥រូប។

**៤. របៀបវារៈ៖**

៤.១ មតិស្វាគមន៍ និងគោលបំណងរបស់ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

៤.២ បទបង្ហាញស្តីពី"ការពិនិត្យមើលរបាយការណ៍វឌ្ឍនភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ក្នុងប្រទេសកម្ពុជា ប្រចាំឆមាសទី១ ឆ្នាំ២០២៤" ដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

៤.៣ មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**៥. សកម្មភាព និងលទ្ធផល ៖**

ជាកិច្ចចាប់ផ្តើម **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះសមាជិក សមាជិកានៃកិច្ចប្រជុំ និងបានបញ្ជាក់ថា ជំងឺអេដស៍នៅតែជាចំណុចអាទិភាព ជាទិសដៅគួរឱ្យបារម្ភគឺ គោលដៅ៩៥ទីមួយ ដែលមិនទាន់ទទួលបានលទ្ធផលល្អនៅឡើយ។

ហេតុដូច្នេះ តើយើងគួររកវិធីសាស្ត្រ ឬមធ្យោបាយយ៉ាងណា ដើម្បីសម្រេចគោលដៅ៩៥ទីមួយ នៅឆ្នាំ២០២៥។ បទអន្តរាគមន៍បង្ការដែលមានលក្ខណៈសុក្រឹតជាក់លាក់ក្នុងការយកមកប្រើប្រាស់ ដើម្បីសម្រេចបាននូវការសម្រេចចិត្តបានត្រឹមត្រូវ និងទាន់ពេលវេលា ដែលផ្តោតទៅលើគោលនយោបាយលុបបំបាត់ការឆ្លងរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍សម្រេចគោលដៅ ៩៥ ៩៥ ៩៥ នៅឆ្នាំ២០២៥ និងចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

**ឯកឧត្តមបណ្ឌិត ឈឹម យិនដារ៉េត** បានបង្ហាញពីសកម្មភាព និងសមិទ្ធផលចម្បងៗ នៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ រយៈពេល៦ខែ នៃ ឆមាសទី១ ឆ្នាំ២០២៤។ សកម្មភាពចំបងៗមាន៖

- បច្ចុប្បន្នភាពនៃស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា។
- សកម្មភាព និងសមិទ្ធផលចម្បងៗ នៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ សម្រាប់ឆមាសទី១ ឆ្នាំ២០២៤។
- បញ្ហាប្រឈម
- ទិសដៅអនុវត្តបន្ត

ផ្អែកតាមសេចក្តីព្រាង ស្តីពីការពិនិត្យមើលរបាយការណ៍វឌ្ឍនភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ក្នុងប្រទេសកម្ពុជា ប្រចាំឆមាសទី១ ឆ្នាំ២០២៤ ក្នុងរយៈពេលថ្មីៗនេះ យើងទទួលបានលទ្ធផលគួរជាទីមោទនៈធំៗរួមមាន៖

- គោលនយោបាយជាតិបញ្ចប់អេដស៍ និងចីរភាពកម្មវិធីអេដស៍សម្រាប់ឆ្នាំ២០២៣-២០២៨ ។
- ផែនទីចង្អុលផ្លូវឆ្ពោះទៅការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា ឆ្នាំ២០២៤-២០៣៥។
- ផែនការយុទ្ធសាស្ត្រជាតិ ទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ លើកទី៦ ឆ្នាំ២០២៤-២០២៨។
- កម្ពុជាបានសម្រេចគោលដៅ ៩៥-៩៥-៩៥ ចំនួនពីររួចហើយ គោលដៅ៩៥ទី២ បាន៩៩% និង៩៥ទី៣ បាន៩៨% ចំណែក៩៥ទី១ បាន៨៦% នៅឡើយ (ឆ្នាំ២០២២) និងកំពុងស្ថិតលើដំណើរផ្លូវត្រូវក្នុងការឆ្ពោះទៅសម្រេចគោលដៅ ៩៥-៩៥-៩៥ ។
- ធ្វើការនវានុវត្តការងារ បង្ការ ថែទាំ និងព្យាបាលជំងឺអេដស៍ក្នុងវិស័យសុខាភិបាល ឆ្នាំ២០២១-២០២៥។
- ពង្រីក ពង្រឹង និងពន្លឿនកម្មវិធីព្យាបាល ថែទាំអ្នកផ្ទុកមេរោគអេដស៍។
- ពង្រីក ពង្រឹង និងពន្លឿនកម្មវិធីគាំពារសង្គម (បណ្ណសមធម៌សុខាភិបាលដល់អ្នកផ្ទុកមេរោគអេដស៍)។
- ការពង្រឹងយន្តការឆ្លើយតបជាពហុវិស័យទាំងវិស័យសុខាភិបាល ស្ថាប័ននានា និងអង្គការពាក់ព័ន្ធ។
- ការបញ្ចប់ការមាក់ងាយ និងការរើសអើង បានរៀបចំផែនការសកម្មភាពសម្រាប់ការឆ្លើយតបនឹងមេរោគអេដស៍ទាក់ទងនឹងការមាក់ងាយនឹងការរើសអើង ដោយផ្តោតលើវិស័យសុខាភិបាល វិស័យអប់រំ និងសហគមន៍។

- អត្រាឆ្លងថ្មីនៃមេរោគអេដស៍ និងអត្រាប្រេវ៉ាឡង់ជំងឺកាមរោគ មានកម្រិតខ្ពស់ក្នុងចំណោមក្រុមប្រឈមមុខខ្ពស់ ជាពិសេសក្រុមប្រជាជនគន្លឹះជាយុវវ័យ។
- អត្រានៃអ្នកដឹងអំពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួន ទើបតែសម្រេចបាន ៨៦% (ឆ្នាំ២០២២) ធៀបនឹងគោលដៅ (៩៥% ទី១)។
- ការទទួលបានសេវាបង្ការការឆ្លងមេរោគអេដស៍ (ជាពិសេស សេវា PrEP) និងសេវាធ្វើតេស្តរកមេរោគអេដស៍ក្នុងចំណោមក្រុមប្រឈមមុខ នៅមានកម្រិត។

  បញ្ហាប្រឈម ៖ មានការលេចឡើងនូវឥរិយាបទប្រឈមថ្មីៗ ដូចជាការប្រើប្រាស់បណ្តាញសង្គម (Social Media) ដើម្បីស្វែងរកដៃគូរួមភេទ ក្រុមអ្នកប្រើគ្រឿងញៀននៅពេលរួមភេទ (Chemsex) ដែលមិនបានបង្ការពីការឆ្លងមេរោគអេដស៍។

ក្នុងឱកាសនោះ **ឯកឧត្តមបណ្ឌិត** ប្រធានអង្គប្រជុំបានបន្តទៀតថា ទន្ទឹមនឹងលទ្ធផលដែលទទួលបានខាងលើ យើងក៏មានឧបសគ្គមួយចំនួនដែលត្រូវប្រឹងប្រែងបន្តគ្រប់ទីកន្លែង គ្រប់ស្ថាប័ន ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អង្គការពាក់ព័ន្ធ វិស័យឯកជន ដើម្បីរួមគ្នាដោះស្រាយ។ សព្វថ្ងៃនេះ តាមការអង្កេតរបស់ក្រសួងសុខាភិបាលបានបញ្ជាក់ថា អត្រាឆ្លងថ្មីនៃមេរោគអេដស៍នៅខ្ពស់នៅឡើយទៅលើក្រុមយុវវ័យ ស្ត្រីបម្រើសេវាកម្សាន្តសប្បាយ ជាពិសេសក្រុមបុរសរួមភេទជាមួយបុរស។ ឯកឧត្តមបានបញ្ជាក់ថា ៩៥%ទីមួយ ទទួលបានតែ៨៦% មិនទាន់បានសម្រេចគោលដៅនៅឡើយ ដូចនេះសូមសមាជិកក្រុមប្រឹក្សាបច្ចេកទេសទាំងអស់ដែលជាសេនាធិការ ត្រូវតែធ្វើការសិក្សារៀបចំផែនការសកម្មភាព និងផែនការថវិកាឱ្យបានទាន់ពេលវេលាតាមការកំណត់នៃសារាចរណ៍ស្តីពីការរៀបចំថវិកាឆ្នាំ២០២៥-២០២៧ និងការរៀបចំសេចក្តីព្រៀងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ២០២៥។ កិច្ចប្រជុំបានឯកភាពលើសេចក្តីព្រាងរបាយការណ៍វឌ្ឍនភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ក្នុងប្រទេសកម្ពុជាប្រចាំឆមាសទី១ ឆ្នាំ២០២៤ និងលើកយកទៅបង្ហាញនៅក្នុងកិច្ចប្រជុំពេញអង្គដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៤ ខាងមុខនេះ។

ជាទីបញ្ចប់នៃកិច្ចប្រជុំ **ឯកឧត្តមបណ្ឌិត** ប្រធានអង្គប្រជុំ បានជូនពរដល់សមាជិកអង្គប្រជុំ សូមជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃចន្ទ ៥រោច ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៤

**បានឃើញ និងឯកភាព**
**ប្រធានអង្គប្រជុំ**

បណ្ឌិត ឈឹម យិនដារ៉េត

**បានពិនិត្យត្រឹមត្រូវ**
**ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន**

វេជ្ជ. ហួត សេរីវង្ស

អ្នកធ្វើរបាយការណ៍

ស៊ុំ ផល្លា